# របាយការណ៍ប្រចាំខែមេសា ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ

នៅក្នុងខែមេសា ឆ្នាំ២០១៥ មន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ បានបំពេញភារកិច្ចសម្រេចលទ្ធផលដូចខាងក្រោម÷

1. **<u>ស្ថានភាពមន្ត្រីរាជការ</u>÷**

ស្ថានភាពមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះសរុបចំនួន ៣០ នាក់ ស្ត្រី ០៤ នាក់ និងដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអនុប្រធានមន្ទីរ ០២ រូប ។

2. **<u>សកម្មភាពថ្នាក់ដឹកនាំមន្ទីរ</u>÷**

- ចូលរួមប្រជុំ ស្ដីពី ការអនុវត្តការងាររបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ថ្ងៃទី ២៥/០៣/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមវេទិកាសាធារណៈនៅ÷
    - ក្រុងក្រចេះ ថ្ងៃទី២៧/០៣/២០១៥ នៅសង្កាត់កោះទ្រង់ ក្រុងក្រចេះ
    - ស្រុកឆ្លូង ថ្ងៃទី១០/០៤/២០១៥ នៅឃុំដំរីផុង ស្រុកឆ្លូង
- ចូលរួមប្រជុំពិគ្រោះយោបល់សម្រាប់គម្រោងធ្វើអាជីវកម្មរ៉ែលោហៈរបស់ក្រុមហ៊ុន KHOV PRIMSEC CO, LTD នៅថ្ងៃទី២៧/០៣/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីសម្ពោធ ឆ្លងសមិទ្ធិផលនានានៅវត្តតាម៉ៅ ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ នៅថ្ងៃទី២៨/០៣/២០១៥ និងនៅវត្តមញ្ជាសិលាថ្មគ្រែ ឃុំថ្មគ្រែ ស្រុកចិត្របុរី ថ្ងៃទី២៩/០៣/២០១៥
- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ថ្ងៃទី៣០/០៣/២០១៥ នៅសាលប្រជុំមន្ទីរអប់រំខេត្ត
- ចូលរួមសូត្រមន្តឆ្លងចូលឆ្នាំមមែ សប្តស័កព.ស២៥៥៩ និងបំពាក់គ្រឿងឥស្សរិយសការងារ ប្រគល់លិខិតសរសើរ ប័ណ្ណសរសើរដល់មន្ត្រីរាជការ នៅថ្ងៃទី០៣/០៤/២០១៥ នៅសាលមហោស្រពខេត្ត
- ចូលរួមក្នុងពិធីសម្ពោធឆ្លងឧបដ្ឋានសាលានៅវត្តពោធិសត្ថារ៉ាម ហៅហុងឡាំ សង្កាត់អូរឬស្សី ក្រុងក្រចេះ ថ្ងៃទី០៤/០៤/២០១៥
- ចូលរួមប្រជុំគណៈកម្មការនាយកមូលនិធិសមធមិប្រចាំត្រីមាសទី១ ឆ្នាំ២០១៥ នៅមន្ទីរពេទ្យបង្អែកឆ្លូង ថ្ងៃទី០៩/០៤/២០១៥ និងមន្ទីរពេទ្យបង្អែកខេត្ត នៅថ្ងៃទី១០/០៤/២០១៥
- ចូលរួមប្រជុំបូកសរុបការងារប្រចាំត្រីមាសទី១ ឆ្នាំ២០១៥ នៅថ្ងៃទី០៩/០៤/២០១៥ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី១០/០៤/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
- ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីសម្ពោធឆ្លងសមិទ្ធិផលនានា នៅវត្តមុនីសាគរ ឃុំពង្រ ស្រុកឆ្លូង ថ្ងៃទី ១១/០៤/២០១៥ និងបានឧបត្ថម្ភបុណ្យចំនួន២០$ (ម្ភៃដុល្លារអាមេរិក)

- ចូលរួមចែករង្វាន់ ដល់សិស្សពូកែក្នុងខេត្ត នៅថ្ងៃទី២០/០៤/២០១៥ ក្នុងនោះមន្ទីរបានឧបត្ថម្ភជាថវិកាចំនួន ៥០ ០០០៛(ហាសិបពាន់រៀល)
- ចូលរួមប្រជុំសាមញ្ញលើកទី១១ អាណត្តិទី២ ឆ្នាំទី១ របស់ក្រុមប្រឹក្សាខេត្ត ថ្ងៃទី២១/០៤/២០១៥ នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត ។

3. <u>សកម្មភាពតាមការិយាល័យ</u>÷

3.1. <u>ការិយាល័យរដ្ឋបាល និងបុគ្គលិក</u>÷

ក. <u>ផ្នែកការងារលិខិតចូល</u> ÷ សរុបចំនួន ៥៧ លេខ ក្នុងនោះមានៈ

- លិខិតរបស់រាជរដ្ឋាភិបាល ចំនួន ០៣លេខ
- លិខិតរបស់ក្រសួងសាម៉ី ចំនួន ០៤លេខ
- លិខិតក្រសួងនានា ចំនួន ០៣ លេខ
- លិខិតផ្សេងៗក្នុងខេត្ត ចំនួន ៤៧លេខ

ខ. <u>ផ្នែកការងារលិខិតចេញ</u>÷ សរុបចំនួន ២២ លេខ ក្នុងនោះមានៈ

- លិខិតទៅនាយកដ្ឋាន និងក្រសួង ចំនួន ០៤ លេខ
- លិខិតផ្សេងៗទូទៅ ក្នុងខេត្ត ចំនួន ១៨ លេខ

គ. <u>ផ្នែកការងារលិខិតបញ្ជាបេសកកម្ម</u>÷ សរុបចំនួន ០៧ លេខ

- ធ្វើសំណើសុំលិខិតបញ្ជាបេសកម្មលោកប្រធានមន្ទីរពី **ឯកឧត្តមអភិបាលខេត្ត** ចំនួន០១ លេខ
- ចេញលិខិតបញ្ជាបេសកកម្មជូនមន្ត្រីចំនួន ០៦ លេខ

ឃ. <u>ផ្នែកបញ្ជីវត្តមាន</u>÷ ពិនិត្យការចុះបញ្ជីវត្តមានជាប្រចាំថ្ងៃ ។

3.2. <u>ការិយាល័យផ្លូវលំជនបទ</u>÷

- <u>សកម្មភាពការងារ</u>
  - ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ប្រវែង៤៦,៨០ គ.ម ស្ថិតនៅឃុំក្បាលដំរី ឃុំរលួសមានជ័យ ឃុំស្រែជិះ ស្រុកសំបូរ
  - ចុះស្រង់ទិន្នន័យផ្លូវបាន ៦ខ្សែ ប្រវែង ១០,៣៦៧ គ.ម នៅស្រុកស្នួល ស្រុកព្រែកប្រសព្វ ស្រុកឆ្លូង
  - ចុះពិនិត្យទីតាំងគម្រោងផ្លូវថែទាំជាលក្ខណៈខួប ឆ្នាំ២០១៥ ស្ថិតនៅឃុំឃ្សឹម ឃុំស្នួល ស្រុកស្នួល ជាមួយក្រុមការងារអន្តរក្រសួង (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
  - ចុះពិនិត្យការងារជួសជុលផ្លូវថែទាំលក្ខណៈខួប សោប-ស្រែងៀត ប្រវែង១១,៧០គ.ម ស្ថិតនៅឃុំសោប ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ បានចំនួន៤លើក
  - ចុះពិនិត្យការងារជួសជុលផ្លូវថែទាំលក្ខណៈខួប វឌ្ឍនៈ-យាវ ប្រវែង ៩,៦០ គ.ម ស្ថិតនៅឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរបាន ០៣ លើក ។

- <u>លទ្ធផលការងារ</u>
  - ការងារជួសជុលផ្លូវថែទាំលក្ខណៈខួប ផ្លូវសោប - ស្រែង្វៀត ប្រវែង ១១,៧០គ.ម ស្ថិតនៅឃុំសោប ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ សម្រេចបាន ៧០%
  - ការងារជួសជុលផ្លូវថែទាំលក្ខណៈខួប វឌ្ឍនៈ - យាវ ប្រវែង ៩,៦០ គ.ម ស្ថិតនៅឃុំវឌ្ឍនៈ ឃុំសំបូរ ឃុំកំពង់ចាម ស្រុកសំបូរ សម្រេចបាន ៧០% ។

3.3. <u>ការិយាល័យផ្គត់ផ្គង់ទឹកជនបទ</u>÷ (គ្មានសកម្មភាព)

3.4. <u>ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u>÷ (គ្មានសកម្មភាព)

3.5. <u>ការិយាល័យអភិវឌ្ឍន៍សហគមន៍</u>÷ (គ្មានសកម្មភាព)

3.6. <u>ការិយាល័យជនជាតិដើមភាគតិច</u>÷ (គ្មានសកម្មភាព)

3.7. <u>ការិយាល័យថែទាំសុខភាពជនបទ</u>÷ (គ្មានសកម្មភាព)

3.8. <u>ការងារបណ្តុះបណ្តាលមន្ត្រីរាជការ</u>÷

- មន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ ចំនួន ១៥ រូប បានចូលរួមសិក្ខាសាលា ស្តីពីដំណោះស្រាយជម្លោះ រយៈពេល ០៣ ថ្ងៃ ចាប់ពីថ្ងៃទី ០៦ ដល់ថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០១៥ រៀបចំដោយអង្គការផៃហ្វាន់ នៅសាលប្រជុំមន្ទីរ ។
- លោក ឈាង ស៊ីថា អនុប្រធានការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ បានចូលរួមសិក្ខាសាលា ស្តីពី ការកែសម្រួលឯកសារឧបករណ៍វាយតម្លៃគូរផែនទីដោយមានការចូលរួម ចាប់ពីថ្ងៃទី ០៧ ដល់ថ្ងៃទី ១០ ខែមេសា ឆ្នាំ ២០១៥ រៀបចំដោយអង្គការ Plan អន្តរជាតិ សាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម ។

4. <u>ទិសដៅបន្ត</u>÷

- បន្តចុះស្រង់ទិន្នន័យផ្លូវតាមប្រព័ន្ធ GPS ចុះធ្វើបច្ចុប្បន្នភាពផ្លូវ ស្រុកព្រែកប្រសព្វ ដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌផ្លូវ និងផែនទីក្នុងខេត្តក្រចេះ ។

**ប្រធានមន្ទីរ**